ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០១៦ សណន

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនដោយខុសច្បាប់ និងការលួចលាក់នាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់

ដើម្បីធានារក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គម ក្រសួងមហាផ្ទៃបានដាក់ចេញគោលការណ៍ និងវិធានការជាបន្តបន្ទាប់ ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពនាំមនុស្សឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងការគ្រប់គ្រងជនបរទេស ស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះ ក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជាកំពុងប្រឈមនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានរឹតត្បិតការធ្វើដំណើរចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ហើយថ្មីៗនេះ ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល និងផ្នែកខ្លះនៃភូមិសាស្ត្រតាមខេត្តមួយចំនួន ត្រូវបានបិទខ្ទប់ជាបណ្តោះអាសន្ន ដើម្បីបង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺនេះក្នុងសហគមន៍។

ផ្អែកលើគោលការណ៍ និងវិធានការខាងលើនេះ អាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ បានប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានការគាំទ្រ ការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានក្នុងសង្គម។

ទោះបីយ៉ាងនេះក្តី ក្រសួងមហាផ្ទៃបានកត់សម្គាល់ឃើញករណីនៃការនាំពលរដ្ឋកម្ពុជា និងជនបរទេសឆ្លងកាត់ព្រំដែនដោយខុសច្បាប់ នៅតែកើតមានជាបន្តបន្ទាប់ ក្នុងនោះ ក៏មានករណីមួយចំនួនមានក្រុមមេក្លោង និងមេខ្យល់ក្នុងស្រុក ឃុបឃិតជាមួយក្រុមមេក្លោង និងមេខ្យល់ពីខាងក្រៅ ដើម្បីរត់ពន្ធមនុស្សឆ្លងកាត់ព្រំដែនដោយខុសច្បាប់ផងដែរ។ ទន្ទឹមនេះ ក៏មានសកម្មភាពលួចលាក់ដឹកជញ្ជូនជនបរទេសចេញ-ចូលភូមិសាស្ត្របិទខ្ទប់ ក្នុងគោលបំណង និងគោលដៅផ្សេងៗគ្នា ដោយគេចចេញពីការធ្វើចត្តាឡីស័កតាមវិធានសុខាភិបាល ដែលអាចបង្កឱ្យមានហានិភ័យក្នុងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ និងប៉ះពាល់ដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងសង្គមថែមទៀត។

ផ្តើមចេញពីសភាពការណ៍ និងសកម្មភាពខាងលើនេះ ក្រសួងមហាផ្ទៃសូមណែនាំដល់អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត នូវវិធានការសំខាន់ៗមួយចំនួន ដើម្បីលុបបំបាត់ការនាំមនុស្សចេញ-ចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងការគ្រប់គ្រងជនបរទេស ដូចខាងក្រោម៖

១. អគ្គស្នងការដ្ឋាននគរបាលជាតិត្រូវដឹកនាំសម្របសម្រួលជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តជាប់ព្រំដែន និងអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ធ្វើការត្រួតពិនិត្យវាយតម្លៃអំពីការអនុវត្តវិធានការនានាក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបការនាំពលរដ្ឋកម្ពុជា និងជនបរទេសចេញ-ចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងបទល្មើសនានាឆ្លងកាត់ព្រំដែន ដើម្បីដាក់ចេញនូវផែនការសកម្មភាពអនុវត្តបន្ត ប្រកបដោយប្រសិទ្ធភាពថែមទៀត។

ក្នុងនោះ ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវបង្ក្រាបបណ្តាញមេក្លោង និងមេខ្យល់ក្នុងប្រទេសដែលធ្វើសកម្មភាពនាំពលរដ្ឋកម្ពុជា និងជនបរទេសឆ្លងកាត់ព្រំដែនខុសច្បាប់ និងទំនាក់ទំនងជាមួយអាជ្ញាធរ និងកម្លាំងមានសមត្ថកិច្ចនៃប្រទេសជិតខាង ដើម្បីសហការបង្ក្រាបបណ្តាញមេក្លោង និងមេខ្យល់ពីខាងក្រៅ សំដៅកាត់ផ្តាច់ខ្សែរយៈទំនាក់ទំនងប្រព្រឹត្តបទល្មើសនេះ។ ទន្ទឹមនេះ ត្រូវបន្តខិតខំសហការស្រាវជ្រាវលុបបំបាត់ឱ្យបានជាដាច់ខាតនូវការលួចចេញ-ចូលតាមច្រកមិនផ្លូវការនៅតាមខ្សែបន្ទាត់ព្រំដែន ព្រមទាំងធ្វើការពិនិត្យ និងរៀបចំនូវកម្លាំងឈរជើងឱ្យបានសមស្រប ដើម្បីល្បាតត្រួតពិនិត្យទប់ស្កាត់ការលួចចេញ-ចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់ នៅតាមខ្សែបន្ទាត់ព្រំដែនដែលមានភូមិសាស្ត្រស្មុគស្មាញ។

២. អគ្គនាយកដ្ឋានអន្តោប្រវេសន៍ត្រូវបង្កើនការគ្រប់គ្រងការចេញ-ចូលតាមច្រកទ្វារព្រំដែន និងភូមិសាស្ត្រទទួលខុសត្រូវតាមច្រកទ្វារព្រំដែននីមួយៗ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបការចេញ-ចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងត្រូវសហការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩។

៣. អភិបាលខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាងត្រូវពង្រឹងមន្ត្រី និងកម្លាំងមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនទ្វេភាគី និងច្រកទ្វារតំបន់ព្រំដែន ឱ្យបង្កើនការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងការចេញ-ចូលឆ្លងកាត់ព្រំដែន និងភូមិសាស្ត្រទទួលខុសត្រូវតាមច្រកទ្វារព្រំដែននីមួយៗ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបការចេញ-ចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងសហការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការនានារបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩។

៤. អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គលេខាធិការដ្ឋានត្រូវសហការទំនាក់ទំនងជាមួយសមភាគីរបស់ខ្លួន នៃបណ្តាប្រទេសក្នុងតំបន់ រួមទាំងប្រទេសជិតខាងកម្ពុជា ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការបង្ក្រាបមេក្លោង និងមេខ្យល់នាំមនុស្សឆ្លងកាត់ព្រំដែនដោយខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទឆ្លងកាត់ព្រំដែន។

អភិបាលខេត្តជាប់ព្រំដែនត្រូវបង្កើនទំនាក់ទំនងជាមួយអភិបាលខេត្តនៃប្រទេសជិតខាងដែលមានព្រំដែនជាប់គ្នា ដោយផ្អែកលើគោលការណ៍នានាដែលបានឯកភាពគ្នា ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពនៅតាមតំបន់ព្រំដែន ការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនាំមនុស្សឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ការរួមគ្នាបង្ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមតំបន់ព្រំដែននៃខេត្តនីមួយៗ ព្រមទាំងការលើកកម្ពស់សហប្រតិបត្តិការក្នុងការផ្លាស់ប្តូរទំនិញកសិផល គ្រឿងឧបភោគបរិភោគនៅតាមតំបន់ព្រំដែន សំដៅរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩។

៥. អគ្គនាយកដ្ឋានអន្តោប្រវេសន៍ត្រូវសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើនការគ្រប់គ្រងជនបរទេស ដោយត្រូវអនុវត្តវិធានការច្បាប់តឹងរឹង ធ្វើការបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេសដែលជ្រៀតចូលមកក្នុងប្រទេសដោយខុសច្បាប់ និងត្រូវពង្រឹងការគ្រប់គ្រង ការត្រួតពិនិត្យការស្នាក់នៅរបស់ជនបរទេស ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ និងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ត្រួតពិនិត្យជនបរទេសដែលតម្រូវឱ្យធ្វើចត្តាឡីស័ក និងជនបរទេសដែលបាននិងកំពុងព្យាបាលជំងឺកូវីដ-១៩ សំដៅធានាអនុវត្តឱ្យបានត្រឹមត្រូវនូវវិធានសុខាភិបាល ស្របតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសុខាភិបាល។

ក្នុងដំណើរការស្រាវជ្រាវការគ្រប់គ្រងជនបរទេស ករណីរកឃើញក្រុមហ៊ុន រោងចក្រ សហគ្រាស ឬបុគ្គលណាដែលមានការពាក់ព័ន្ធក្នុងបទល្មើសនាំមនុស្សឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ឬទទួលមនុស្សឆ្លងដែនខុសច្បាប់ឱ្យធ្វើការ ត្រូវចាត់វិធានការច្បាប់ឱ្យបានម៉ឺងម៉ាត់បំផុត។

៦. ក្នុងកិច្ចប្រតិបត្តិការគ្រប់គ្រងការចេញ-ចូលឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ករណីរកឃើញការលួចជ្រៀតចូលដោយខុសច្បាប់នៅចំណុចណាមួយ មន្ត្រី កងកម្លាំងមានសមត្ថកិច្ចនៅតាមច្រកទ្វារ និងកងកម្លាំងល្បាតការពារព្រំដែនត្រូវចាត់វិធានការបញ្ជូនចេញតាមចំណុចនោះនៅនឹងកន្លែងភ្លាម។ ករណីរកឃើញជនបរទេសដែលឆ្លងកាត់ព្រំដែនដោយខុសច្បាប់បានជ្រៀតចូលជ្រៅមកក្នុងប្រទេស ត្រូវធ្វើការឃាត់ខ្លួន ហើយត្រូវសហការឱ្យអនុវត្តវិធានការចត្តាឡីស័ក ស្របតាមវិធានសុខាភិបាល និងត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៧. អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាពិសេសរដ្ឋបាលឃុំ សង្កាត់ និងអាជ្ញាធរភូមិ ព្រមទាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើនកិច្ចសហការក្នុងការគ្រប់គ្រងការចេញ-ចូល ស្នាក់នៅរបស់ជនបរទេសនៅតាមមូលដ្ឋានរបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងខិតខំសហការចូលរួមក្នុងការស្រាវជ្រាវបង្ក្រាបមេក្លោង និងមេខ្យល់រត់ពន្ធមនុស្សឆ្លងកាត់ព្រំដែនដោយខុសច្បាប់ នៅតាមមូលដ្ឋាននានាទូទាំងប្រទេស ក៏ដូចជនបរទេសដែលបំពានវិធានការរបស់រាជរដ្ឋាភិបាលក្នុងការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល និងសេចក្តីសម្រេចពាក់ព័ន្ធ របស់រដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ទន្ទឹមនេះ ត្រូវផ្សព្វផ្សាយ អប់រំ បំផុសប្រជាពលរដ្ឋតាមឃុំ សង្កាត់ ភូមិនីមួយៗ ឱ្យចូលរួមក្នុងការងារខាងលើនេះឱ្យបានសកម្មផុលផុសនៅគ្រប់មូលដ្ឋានទូទាំងប្រទេស។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមស្មារតីខាងលើឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ពុធ ០២រោច ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ